# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលការកំណត់របបឧបត្ថម្ភ និងរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ជូនកងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្ករស្លាប់ បាត់ខ្លួន និង ពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៧ នស.៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីរបបឧបត្ថម្ភគោលនយោបាយ ចំពោះមន្ត្រីនគរបាល ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- យោងតាមការចាំបាច់

# សម្រេច

**មាត្រា ១-**

អនុក្រឹត្យនេះ មានគោលដៅកែសម្រួលការកំណត់របបឧបត្ថម្ភ និងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ជូនកងយោធពលខេមរភូមិន្ទ និង កងកម្លាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ។

**មាត្រា ២-**

ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ ជូនកងយោធពលខេមរភូមិន្ទ និងកងកំលាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ដែលបានកំណត់នៅក្នុងអនុក្រឹត្យ ឬ បទបញ្ញាទាំងឡាយពាក់ព័ន្ធនឹងរបបឧបត្ថម្ភដោយផ្អែកលើប្រាក់បៀវត្សចុងក្រោយ ឬ ប្រាក់បៀវត្សសរុបចុងក្រោយ ត្រូវបានកែសម្រួលមកជារបបឧបត្ថម្ភដោយផ្អែកលើប្រាក់បៀវត្សមូលដ្ឋានចុងក្រោយវិញ ។

**មាត្រា ៣-**

ប្រាក់សោធននិវត្តន៍ និងប្រាក់សោធនបាត់បង់សមត្ថភាពការងារ ជូនយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា ៨ នៃជំពូកទី ២ និងមាត្រា ១៤ នៃជំពូកទី ៣ នៃអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ត្រូវបានកែសម្រួលមកជាប្រាក់សោធននិវត្តន៍ និងប្រាក់សោធនបាត់បង់សមត្ថភាពការងារ ដែលមានតែប្រាក់បៀវត្សមូលដ្ឋានចុងក្រោយប៉ុណ្ណោះ ។

**មាត្រា ៤-**

អនុក្រឹត្យនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១០ ។

**មាត្រា ៥-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ